ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឧត្តមភាពរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

Shared by page: Mr. That Chantha
https:///www.facebook.com/thatchantha

# ឧត្តមភាពនៃរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ គឺជាលក្ខខណ្ឌគតិយុត្តនៃរដ្ឋ។ តាមន័យសម្ភារៈ រដ្ឋធម្មនុញ្ញគឺជាច្បាប់គ្រឹះ និងជាច្បាប់កំពូលនៃរដ្ឋ ដែលជាទូទៅកំណត់នូវរចនាសម្ព័ន្ធ និងមុខងារជាមូលដ្ឋាននៃរដ្ឋនិងអង្គការសំខាន់ៗព្រមទាំងកំណត់នូវសិទ្ធិ និងករណីកិច្ចជាមូលដ្ឋានរបស់ពលរដ្ឋ។ ចំណែកឯន័យទម្រង់វិញ រដ្ឋធម្មនុញ្ញ គឺជាឯកសារដែលនិយាយអំពីស្ថាប័ននយោបាយ ដែលគេរៀបចំតាក់តែងឡើង និងធ្វើវិសោធនកម្មគោរពតាមនីតិវិធីខុសពីនីតិវិធីសម្រាប់ច្បាប់ធម្មតា។ តាមន័យទាំងនេះយើងអាចដឹងថារដ្ឋធម្មនុញ្ញពិតជាមានឧត្តមភាព។ តើឧត្តមភាពនៃរដ្ឋធម្មនុញ្ញជាអ្វី? តើរដ្ឋធម្មនុញ្ញឧត្តមភាពយ៉ាងណាខ្លះ?

## ១. កំណត់ន័យឧត្តមភាពនៃរដ្ឋធម្មនុញ្ញ

នៅក្នុងពាក្យឧត្តមភាពនៃរដ្ឋធម្មនុញ្ញយើងឃើញមានពាក្យគន្លឹះមួយសំខាន់គឺ "ឧត្តមភាព" ។ អ្វីទៅជាឧត្តមភាព? ពាក្យឧត្តមភាពគឺសំដៅដល់ភាពជាធំ ភាពខ្ពង់ខ្ពស់ ប្រសើរលើសគេ។ តាមរយៈន័យនេះ យើងអាចកំណត់ន័យ "ឧត្តមភាពនៃរដ្ឋធម្មនុញ្ញ" បានថាជាភាព ដែលមានតម្លៃគតិយុត្តខ្ពង់ខ្ពស់ជាងគេ នៃរដ្ឋធម្មនុញ្ញ។ ក្នុងន័យនេះឧត្តមានុភាពនៃរដ្ឋធម្មនុញ្ញគឺស្ថិតនៅទីតាំងទីមួយនៃឋានានុក្រមច្បាប់។

## ២. ឧត្តមភាពតម្លៃគតិយុត្តនៃរដ្ឋធម្មនុញ្ញ

ដោយយោងទៅលើ ឧត្តមភាពនៃតម្លៃគតិយុត្តដែលខ្ពង់ខ្ពស់ជាងគេ បើប្រៀបធៀបទៅនឹងច្បាប់ផ្សេងៗ លោក Hans Kelsen បានចាត់ថ្នាក់ឲ្យរដ្ឋធម្មនុញ្ញស្ថិតនៅថ្នាក់កំពូលនៃសាជីជ្រុង។ តាមរយៈការចាត់ថ្នាក់នេះយើងឃើញថា តម្លៃគតិយុត្តរបស់រដ្ឋធម្មនុញ្ញមានឧត្តមភាពខ្ពង់ខ្ពស់ណាស់ ដែលច្បាប់ទាំងឡាយនៃរដ្ឋត្រូវតែរណប។ នេះមានន័យថា អត្ថបទច្បាប់ ឬបទបញ្ញាទាំងឡាយត្រូវតែគោរពទៅតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ គោលការណ៍គតិយុត្តនៃច្បាប់ ឬបទបញ្ញាទាំងឡាយរបស់រដ្ឋ មិនអាចផ្ទុយពីគោលការណ៍នៃរដ្ឋធម្មនុញ្ញបានទេ។ ករណីដែលមានការចែងផ្ទុយពីរដ្ឋធម្មនុញ្ញនោះគេនឹងចាត់ទុកអត្ថបទច្បាប់ ឬបទបញ្ញានោះថាអធម្មនុញ្ញភាព ដែលត្រូវតែកែប្រែឬលុបចោល។ ហេតុនេះហើយដើម្បីធានាឲ្យបាននូវការគោរពឧត្តមភាពនៃរដ្ឋធម្មនុញ្ញ គេតម្រូវឲ្យមានការពិនិត្យធម្មនុញ្ញភាព។

រដ្ឋធម្មនុញ្ញកើតឡើងពីអង្គការចាត់តាំងពិសេសមួយខុសប្លែកពីច្បាប់ធម្មតា គឺកើតចេញពីប្រជាមតិ ឬសភាធម្មនុញ្ញ ដែលទាំងនេះកើតចេញពីការអនុវត្តអំណាចរបស់ប្រជាពលរដ្ឋដោយផ្ទាល់ ឬតាមរយៈតំណាងក្នុងការ

បង្កើតរដ្ឋធម្មនុញ្ញឡើង។ នេះបញ្ជាក់ថា បើមានគោលការណ៍ ណាមួយនៃច្បាប់ ឬបទបញ្ញាណាមួយចែងផ្ទុយនឹងរដ្ឋធម្មនុញ្ញនោះ មានន័យថាវាផ្ទុយនឹងឆន្ទៈរបស់ប្រជាពលរដ្ឋ។

ការត្រួតពិនិត្យធម្មនុញ្ញភាព អាចធ្វើជាអាទិកាល ឬជាបុច្ឆាកាល។ តាមមាត្រា១៤០ និង ១៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា: "ច្បាប់អាចត្រូវបានពិនិត្យធម្មនុញ្ញភាពមុននិងក្រោយប្រកាសឲ្យប្រើ។ រីឯបទបញ្ញាផ្ទៃក្នុងរដ្ឋសភា និងច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឲ្យប្រើ"។ នេះគឺជាមាត្រាដែលបានចែងដើម្បីការពារឧត្តមភាពនៃរដ្ឋធម្មនុញ្ញ ដែលការពារមិនឲ្យមានការចែងផ្ទុយ ឬប្រការដែលនាំឲ្យមានគ្រោះថ្នាក់ដល់រដ្ឋធម្មនុញ្ញ។ ពិសេសចំពោះច្បាប់រៀបចំអង្គការនានាដែលរដ្ឋធម្មនុញ្ញត្រូវតែការពារយ៉ាងល្អិតល្អន់ ដោយការត្រួតពិនិត្យធម្មនុញ្ញភាពជាមុន។ ករណីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះផងដែរ យើងក៏ឃើញមានមាត្រាមួយចំនួន បានចែងស្តែងឲ្យឃើញពីឧត្តមភាពគតិយុត្តនៃរដ្ឋធម្មនុញ្ញដូចជា:

មាត្រា១៥០: "រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់និងសេចក្តីសម្រេចនានាត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត"។ មាត្រានេះសង្កត់យ៉ាងធ្ងន់មាន តែរដ្ឋធម្មនុញ្ញមួយគត់ដែលខ្ពស់ជាងគេ ហើយមិនឲ្យមានការចែងផ្ទុយពីគោលការណ៍គតិយុត្តដែលមានចែងក្នុងរដ្ឋធម្មនុញ្ញពីច្បាប់ផ្សេងៗឡើយ។

មាត្រា១៥៨: "ច្បាប់ និងបទដ្ឋានទាំងអស់នៅកម្ពុជាដែលធានាការពារនូវទ្រព្យសម្បត្តិ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល ដែលសមស្របនឹងផលប្រយោជន៍ជាតិត្រូវមានអានុភាពអនុវត្តតទៅទៀតរហូតដល់មានអត្ថបទថ្មីមកចែងកែប្រែឬលុបចោលលើកលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងស្មារតីរដ្ឋធម្មនុញ្ញ"។ មាត្រានេះបានកំណត់តម្លៃគតិយុត្តនៃច្បាប់មុនៗ ដោយមានអត្ថន័យមួយគឺ លុបចោលរាល់ច្បាប់ មុនៗណាដែលផ្ទុយនឹងគោលការណ៍រដ្ឋធម្មនុញ្ញ និង រក្សាទុកនូវច្បាប់ដែលមិនផ្ទុយនឹងរដ្ឋធម្មនុញ្ញ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏មានឧត្តមភាពគតិយុត្តខ្ពស់ជាងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិផងដែរ។ នេះស្តែងឡើងតាម មាត្រា៥៥ ដែលចែងថា: "សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រិត្យភាពនៃព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល"។

### ៣. ឧត្តមភាពនៃនីតិវិធី

យើងឃើញថានីតិវិធីនៃការបង្កើតរដ្ឋធម្មនុញ្ញក្តី នីតិវិធីនៃការធ្វើវិសោធនកម្មក្តី រដ្ឋធម្មនុញ្ញមាននីតិវិធីសាំញ៉ាំ និងតឹងតែងជាងច្បាប់ធម្មតា។ នេះបង្ហាញថារដ្ឋធម្មនុញ្ញមានឧត្តមភាពខ្ពស់ជាងច្បាប់ ធម្មតា។ រដ្ឋធម្មនុញ្ញកើតចេញពីប្រជាមតិ ឬចេញពីសភាធម្មនុញ្ញ ដែលប្រជាពលរដ្ឋប្រើអំណាចរបស់ ខ្លួនដោយផ្ទាល់ ឬតាមរយៈ

តំណាង។ ដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាជារដ្ឋធម្មនុញ្ញរឹង ដូច្នេះ "ការសើរើត្រូវសម្រេចដោយរដ្ឋសភាតាមសម្លេង២/៣ នៃសមាជិករបស់ខ្លួនទាំងមូល" (មាត្រា១៥១វាក្យខណ្ឌទី២)។ សម្លេង២/៣ នេះជាសម្លេងពិបាកនឹងរក ដែលវាជាសញ្ញាបញ្ជាក់ថាបញ្ញត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញមានឧត្តមភាព ខ្ពស់ខ្ពស់មិនងាយនឹងអាចសើរើបាន។

មួយវិញទៀត នៅក្នុងមាត្រា១៥២ និង១៥៣ បានហាមមិនឲ្យមានការសើរើរដ្ឋធម្មនុញ្ញ។ "ការសើរើរដ្ឋធម្មនុញ្ញមិនអាចធ្វើទៅកើតទេក្នុងករណីដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន" (មាត្រា១៥២)។ នេះគឺជាការដាក់កម្រិត នូវសិទ្ធិក្នុងការសើរើ ក្នុងគោលបំណងហាមមិនឲ្យស្ថាប័នផ្សេងៗ បំប្លែងខ្លួនជា ស្ថាប័នផ្សេងទៀតដើម្បីរកចំណេញលើកាលៈទេសៈដែលវឹកវរនោះ។ ការហាមឃាត់មួយទៀតគឺអ្វីដែល "ប៉ះពាល់ដល់របបប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ" (មាត្រា១៥៣)។ ការហាមឃាត់នេះ គឺដើម្បីបង្ហាញពីការរក្សារបបនយោបាយមួយដែលមានស្ថេរភាពសម្រាប់ការដឹកនាំរដ្ឋ។ ជារួម ភាពខុសគ្នានៃតម្លៃគតិយុត្ត និងនីតិវិធី បើប្រៀបធៀបទៅនឹងច្បាប់ដទៃ គឺជាឧត្តមានុភាពរបស់រដ្ឋធម្មនុញ្ញ។

## ៤. សន្និដ្ឋាន

យោងតាមការសិក្សាខាងលើ យើងឃើញថារដ្ឋធម្មនុញ្ញមានឧត្តមភាពខ្ពង់ខ្ពស់ជាងច្បាប់ដទៃ។ រដ្ឋធម្មនុញ្ញជាច្បាប់កំពូលសម្រាប់រដ្ឋនីមួយៗ ដែលនេះបានបង្ហាញឲ្យឃើញថារដ្ឋធម្មនុញ្ញត្រូវតែជាធាតុចម្បងបង្អស់ និងជាធាតុដែលបង្កើតច្បាប់ដទៃទៀតផងដែរ។ គ្រប់បទបញ្ញត្តិនៃអត្ថបទច្បាប់នៃរដ្ឋ គឺជាធាតុចំណុះឲ្យរដ្ឋធម្មនុញ្ញទាំងអស់ មិនអាចមានច្បាប់ដែលផ្ទុយនឹងស្មារតីរដ្ឋធម្មនុញ្ញបានទេ៕

## ៥. ឯកសារពិគ្រោះ


1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។
2. នីតិរដ្ឋធម្មនុញ្ញកម្ពុជា លោកម៉ូរីស ហ្គៃយ៉ា ១៩៩៤ ។
3. នីតិរដ្ឋធម្មនុញ្ញ រៀបរៀងដោយ សាស្ត្រាចារ្យ សុខ យ៉ាន ឆ្នាំសិក្សា២០១១-២០១២ ។


**ចប់**